ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១១១៣ សរឹល

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពីការផ្គត់ផ្គង់ឯកសណ្ឋានសញ្ញាសក្តិ និងសម្ភារផ្សេងៗ របស់មន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ និងមន្ត្រី ពន្ធនាគារ សម្រាប់ប្រើប្រាស់ឆ្នាំ២០១៧

ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស ( គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថាក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ នឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ឯកសណ្ឋានសញ្ញាសក្តិ និងសម្ភារផ្សេងៗ របស់មន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ និងមន្ត្រីពន្ធនាគារ សម្រាប់ប្រើប្រាស់ឆ្នាំ២០១៧ ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ផ្នែករដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងហាផ្ទៃ ដែលមានអាសយដ្ឋានក្នុងទីស្តីការក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោង ធ្វើការ (ឬទាក់ទងតាមទូរស័ព្ទលេខ ០២៣ ៧២៦ ០៤៥) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង ៨:៣០ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៧។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង ៨:៣០ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៧ នៅចំពោះមុខគណៈកម្មការ និងប្រធាន ឬអនុប្រធានក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ផ្នែករដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

**ព័ត៌មានផ្សេងៗសូមទាក់ទង**

-ទូរស័ព្ទលេខ : ០២៣ ៧២៦ ០៤៥

<u>ចំលងជូន</u>

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"